ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ១៩៧/១៦

ខុទ្ទកាល័យសម្តេចក្រឡាហោម ស ខេង
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ចូល
លេខ: 2576
ថ្ងៃ 11.12.16 ម៉ោង
បញ្ជូន: ម៉ោង

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ ២០១៦

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

ជាទីគោរពដ៏ខ្ពង់ខ្ពស់!

**កម្មវត្ថុ÷** សូមគោរពស្នើសុំគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ ដើម្បីអញ្ជើញតំណាងស្ថានទូតបរទេស ដែលមាននិវេសនដ្ឋាន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលរួមកិច្ចប្រជុំពិភាក្សា អំពីករណីធ្វើអំពើ អន្តរការី នៃអំពើពពោះ និងសូមអញ្ជើញ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** ដើម្បីដឹកនាំកិច្ចប្រជុំដ៏ខ្ពង់ខ្ពស់។

**យោង÷** -ចំណារឯកភាពរបស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** លេខ១៨២/១៦ រ.ប.ក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦។

-កំណត់ហេតុកិច្ចប្រជុំ ស្តីពី ករណីធ្វើអន្តរការី នៃអំពើពពោះចំនួន ២លើក។ លើកទី១ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ និងលើកទី២ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦។

-កិច្ចពិភាក្សាថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦ រវាងលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ជាមួយតំណាងស្ថានទូតអូស្ត្រាលី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ បន្ទាប់ពីបានបង្ក្រាបករណី "អំពើធ្វើអន្តរការីសម្រាប់ការពពោះជំនួស" ក្នុងខែវិច្ឆិកាកន្លងមក បានឈានដល់ការស្វែងរកដំណោះស្រាយសមស្របមួយ ដើម្បីជៀសវាងការរីករាលដាល ក្នុងកំឡុងពេលដែលមិនទាន់មានច្បាប់គ្រប់គ្រាន់។ ស្ថានទូតអូស្ត្រាលីបានស្នើសុំឲ្យមានកិច្ចប្រជុំរវាងស្ថានទូតពាក់ព័ន្ធនៅកម្ពុជា ដើម្បីផ្លាស់ប្តូរយោបល់ និងសូមស្នើសុំ **សម្តេចក្រឡាហោម** ដើម្បីដឹកនាំកិច្ចប្រជុំនេះ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើសូម **សម្តេចក្រឡាហោម** មេត្តាអនុញ្ញាតជាគោលការណ៍រៀបចំកិច្ចប្រជុំជាមួយតំណាងស្ថានទូត និងសូមគោរពអញ្ជើញចូលរួមជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ ដើម្បីមានមតិដឹកនាំ ក៏ដូចជាផ្តល់អនុសាសន៍ សម្រាប់យកទៅអនុវត្តឲ្យរឹតតែមានប្រសិទ្ធភាពខ្ពស់។

សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** ទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់បំផុតអំពីនាងខ្ញុំ។

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**KINGDOM OF CAMBODIA**
**NATION RELIGION KING**

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

No. 3035 MFA-IC/LC2

URGENT

The Ministry of Foreign Affairs and International Cooperation presents its compliments to the Australian Embassy in Phnom Penh and, with the reference to the Ministry's note No. 2938 MFA-IC/LC2 dated 08 December 2016, and the meeting between Her Excellency Chou Bun Eng, Secretary of State of the Ministry of Interior and representatives of the Australian Embassy in Phnom Penh on 24 November 2016, regarding the case of surrogacy, has the honor to inform the Embassy as follows:

- The Embassy is kindly requested to suspend issuing Australian passport for the children who were born from surrogate Cambodian women.
- In addition, the Embassy is also requested to cooperate with the Cambodian competent authorities to set up joint procedure to deal with cases already existed. Currently, in conformity with the Cambodian penal code, the intermediary between an adoptive parent and a pregnant woman is prohibited.

The Ministry of Foreign Affairs and International Cooperation avails itself of this opportunity to renew to the Embassy the assurance of its highest consideration. ✳

Phnom Penh, 23 December 2016

Australian Embassy
Phnom Penh

Address : N° 3, **Samdech HUN Sen** Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 214 441, 216 122
Fax : (855) 23 216 144, 216 141
Email : mfaic@mfa.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
មន្ទីរស៊ើបសួរ "ត"
លេខ:.7.0.7.4......"ត" ដ.ព.ស

# ដីកាបង្គាប់ឲ្យឃុំខ្លួន

(មាត្រា ២១៩ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

យើង **រស់ ពិសិដ្ឋ** ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ មាត្រា ២១៩ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាស ឲ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០/០៨/២០០៧។

-បានឃើញមាត្រា ២០៣ ,មាត្រា២០៤ មាត្រា ២០៥ និងមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៥៥៤៩ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៦

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣២៦១ អ.យ.រ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញសំណុំរឿងស៊ើបសួរទាក់ទងនឹង:

-ឈ្មោះ **សំរិទ្ធ ច័ន្ទចរិយា** ភេទស្រី អាយុ ៣៤ឆ្នាំ (៣១-០១-១៩៨២) ជនជាតិខ្មែរ មុខរបរ គិលានុបដ្ឋាក (ពេទ្យឯកជន) សាសនាព្រះពុទ្ធ កើតនៅសង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ន នៅផ្ទះលេខ ៥៥ ផ្លូវលំ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ សំរិទ្ធ សារឿន "រស់" ម្តាយឈ្មោះ យិត សុផល្លា "ស្លាប់" ប្តីឈ្មោះ ដេ មាន (រស់) ០១នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ជានីតិជន។

ជននេះត្រូវបានឃាត់ខ្លួនកាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ និងត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ:**អន្តរការរវាងអ្នកសុំកូន និងស្ត្រីពពោះ** និងបទ សុំឲ្យផ្តល់ឯកសារដោយទុច្ចរិត តាមបញ្ញត្តិមាត្រា៣៣២ និងមាត្រា ៦៣២ នៃក្រមព្រហ្មទណ្ឌ។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣២៦១ អ.យ.រ ចុះថ្ងៃទី២១ ខែវិច្ឆកា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ.....5147.........ដពស/១៦ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦។

## សម្រេច

១.បញ្ជាឲ្យភ្នាក់ងារមានសមត្ថកិច្ចនៃកម្លាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ **សំរិទ្ធ ច័ន្ទចរិយា** ភេទស្រី អាយុ ៣៤ឆ្នាំ (មានសវតាជាតិខាងលើ) ទៅមណ្ឌលអប់រំកែប្រែ ម២ ដោយ អនុវត្តឲ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់។

២.បង្គាប់ឲ្យប្រធានមណ្ឌលអប់រំកែប្រែ ម២ ទទួលជននេះ និងឃុំជននេះ រហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ។

៣.បង្គាប់ឲ្យគ្រប់ភ្នាក់ងារនៃកម្លាំងសាធារណៈទាំងអស់នៅពេលត្រូវបានបង្ហាញដីកានេះ សហការអនុវត្តឲ្យបានល្អនៅ

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦
**ចៅក្រមស៊ើបសួរ**

រស់ ពិសិដ្ឋ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
មន្ទីរស៊ើបសួរ "គ"
លេខៈ...7075.... "គ" ជ.ព.ស

# ដីកាបង្គាប់ឲ្យឃុំខ្លួន

(មាត្រា ២១៩ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

យើង **រស់ ពិសិដ្ឋ** ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ មាត្រា ២១៩ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាស ឲ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០/០៨/២០០៧។

-បានឃើញមាត្រា ២០៣ ,មាត្រា២០៤ មាត្រា ២០៥ និងមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៥៥៤៩ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៦

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣២៦១ អ.យ.រ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញសំណុំរឿងស៊ើបសួរទាក់ទងនឹងៈ

-ឈ្មោះ **ពេញ វិទ្ធី** ភេទប្រុស អាយុ ២៨ឆ្នាំ (០៣-០៣-១៩៨៨) ជនជាតិខ្មែរ មុខរបរ មន្ត្រីរាជការ កើតនៅសង្កាត់មិត្តភាព ខណ្ឌ៧មករា ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្ន នៅផ្ទះលេខ D៥ ផ្លូវលំ សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ ពេញ ពុធ "រស់" ម្តាយឈ្មោះ ទា វិជ្ជយិនី "រស់" ប្រពន្ធឈ្មោះ សុខ ចាន់ (រស់) គ្មានកូន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ជានីតិជន។

ជននេះត្រូវបានឃាត់ខ្លួនកាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ និងត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទៈ **អន្តរការរវាងអ្នកសុំកូន និងស្ត្រីពពោះ និងបទ សុំឲ្យផ្តល់ឯកសារដោយទុច្ចរិត** តាមបញ្ញត្តិមាត្រា ៣៣២ និង មាត្រា ៦៣២ នៃក្រមព្រហ្មទណ្ឌ។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣២៦១ អ.យ.រ ចុះថ្ងៃទី២១ ខែវិច្ឆកា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ.....5148........ជពស/១៦ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦។

## សម្រេច

១.បញ្ជាឲ្យភ្នាក់ងារមានសមត្ថកិច្ចនៃកម្លាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ **ពេញ វិទ្ធី** ភេទប្រុស អាយុ ២៨ឆ្នាំ (មានសវតាជាតិខាងលើ) ទៅមណ្ឌលអប់រំកែប្រែ ម១ ដោយ អនុវត្តឲ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់។

២.បង្គាប់ឲ្យប្រធានមណ្ឌលអប់រំកែប្រែ ម១ ទទួលជននេះ និងឃុំជននេះ រហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ។

៣.បង្គាប់ឲ្យគ្រប់ភ្នាក់ងារនៃកម្លាំងសាធារណៈទាំងអស់នៅពេលត្រូវបានបង្ហាញដីកានេះ សហការអនុវត្តឲ្យបានល្អនៅក្នុងករណីចាំបាច់។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦

**ចៅក្រមស៊ើបសួរ**

រស់ ពិសិដ្ឋ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
មន្ទីរស៊ើបសួរ "គ"
លេខ:.....7073...... "គ" ជ.ព.ស

# ដីកាបង្គាប់ឲ្យឃុំខ្លួន

(មាត្រា ២១៩ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

យើង **រស់ ពិសិដ្ឋ** ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ មាត្រា ២១៩ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាស ឲ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០/០៨/២០០៧។

-បានឃើញមាត្រា ២០៣ ,មាត្រា២០៤ មាត្រា ២០៥ និងមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៥៥៤៩ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៦

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣២៦១ អ.យ.រ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញសំណុំរឿងស៊ើបសួរទាក់ទងនឹង:

-ឈ្មោះ CHARLES TAMMY ALAYNE ភេទស្រី អាយុ ៤៩ឆ្នាំ (៣០-០៧-១៩៦៧) ជនជាតិអូស្ត្រាលី មុខរបរ ជួញគ្រួសារឲ្យមានកូន កើតនៅទីក្រុង វិកតូរៀ ប្រទេសអូស្ត្រាលី មានទីលំនៅបច្ចុប្បន្ន នៅផ្ទះលេខ ៣៨ ជាន់ទី៤ ផ្លូវលេខ ១៨៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ DARY "ស្លាប់" ម្តាយឈ្មោះ PAU LINE "រស់" ប្តីឈ្មោះ SI MON (រស់) ០៦នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ជានីតិជន។

ជននេះត្រូវបានឃាត់ខ្លួនកាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ និងត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ពីបទ: **អន្តរការរវាងអ្នកសុំកូន និងស្ត្រីពពោះ និងបទ សុំឲ្យផ្តល់ឯកសារដោយទុច្ចរិត** តាមបញ្ញត្តិមាត្រា ៣៣២ និង មាត្រា ៦៣២ នៃក្រមព្រហ្មទណ្ឌ។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣២៦១ អ.យ.រ ចុះថ្ងៃទី២១ ខែវិច្ឆកា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ.....5146.........ជពស/១៦ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦។

## សម្រេច

១.បញ្ជាឲ្យភ្នាក់ងារមានសមត្ថកិច្ចនៃកម្លាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ CHARLES TAMMY ALAYNE ភេទស្រី អាយុ ៤៩ឆ្នាំ (មានសវតាជាតិខាងលើ) ទៅមណ្ឌលអប់រំកែប្រែ ម២ ដោយ អនុវត្តឲ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់។

២.បង្គាប់ឲ្យប្រធានមណ្ឌលអប់រំកែប្រែ ម២ ទទួលជននេះ និងឃុំជននេះ រហូតដល់មានបទបញ្ជាថ្មី សម្រេចផ្សេងពីនេះ។

៣.បង្គាប់ឲ្យគ្រប់ភ្នាក់ងារនៃកម្លាំងសាធារណៈទាំងអស់នៅពេលត្រូវបានបង្ហាញដីកានេះ សហការអនុវត្ត ឲ្យបានល្អនៅ

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦
**ចៅក្រមស៊ើបសួរ**

រស់ ពិសិដ្ឋ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខ: ១៨២/១៦ គ.ជ.ប.ក

# សូមគោរពជូន
# សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
# ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ចូល លេខ: ២៥៨៧ ថ្ងៃ: 25.11.16 ម៉ោង បញ្ជាន:

**កម្មវត្ថុ**៖ សូមគោរពជូនសេចក្តីរាយការណ៍ ស្តីពី ការបង្ក្រាបករណីអន្តរការីសម្រាប់ការពរពោះជំនួស និងសូមគោរពស្នើសុំអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ។

សេចក្តីដូចបានជម្រាបជូនខាងលើ នាងខ្ញុំសូមអនុញ្ញាតគោរព រាយការណ៍ជូនសម្តេច ជាទីគោរពដ៏ខ្ពង់ខ្ពស់ដូចខាងក្រោម ៖

ការពរពោះជំនួស បានក្លាយជាប្រធានបទមួយដែលត្រូវបានប្រទេសជាច្រើនពិចារណាជាថ្មី បន្ទាប់ពីបានបង្កើតច្បាប់អនុញ្ញាតឲ្យមានការពរពោះជំនួសនេះរួច ។ ថ្មីៗនេះ នៅព្រំដែនថៃ-ម៉ាឡេស៊ី ប៉ូលិសថៃបានជួយរំដោះក្មេងៗជាច្រើននាក់ ដែលជនល្មើសបានវេចខ្ចប់បំរុងយកទៅលក់នៅក្រៅប្រទេស!តែជាអកុសលកុមាភាគច្រើនត្រូវបានស្លាប់បាត់ទៅហើយ។ អាចជាករណីជួញដូរអវៈយវៈ ឬជួញដូរសេរីរាង្គ ។

មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងបន្ទាប់ពីមានការចូលឆ្នក់ ជួយសង្គ្រោះកុមារមួយក្រុម ដែលត្រៀមជួញដូរទៅប្រទេសចិន។ តាមរយៈវីដេអូរយៈពេល១១វិនាទី បង្ហាញពីការជួយសង្គ្រោះកុមារមួយក្រុម ដែលត្រៀមជួញដូរទៅប្រទេសចិន ធ្វើឲ្យមានការភ័យខ្លាចគ្រប់គ្នា។នេះគឺជាករណីដែលត្រូវប្រុងប្រយ័ត្ន ជាទីបំផុត ។

ដោយឡែក នៅរាជធានីភ្នំពេញ នគរបាលប្រឆាំងការជួញដូរមនុស្ស រាជធានី បាន សហការមួយព្រះរាជអាជ្ញាបង្ក្រាបករណីអំពើធ្វើអន្តរការីសម្រាប់ការពរពោះជំនួស កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលបានធ្វើឲ្យមានការភ្ញាក់ផ្អើល និងមានការចោទជាសំនួរជាច្រើនពីសារព័ត៌មាន ។

ក្នុងនោះ ជំនាញបានរកឃើញថា ជាបទល្មើសពិតប្រាកដ ដែលកើតឡើងពីការឃុបឃិតគ្នារវាងជនជាតិអូស្ត្រាលី និងជនជាតិខ្មែរពីររូប ដែលបានល្បួងស្ត្រីខ្មែរឲ្យដូលពរពោះ និងផ្តល់កម្រៃពី៨.០០០ ទៅ ១០.០០០ដុល្លា ។ ស្ត្រីដែលបានមកពិនិត្យសុខភាពដើម្បីបញ្ចូលមេជីវិត នៅមន្ទីរពេទ្យកម្ពុជា និងមន្ទីរពេទ្យវឌ្ឍនៈ មាន៥២នាក់ តែមានតែ១២នាក់ទេ ដែលទទួលមេជីវិតហើយ មានផ្ទៃពោះ ។ តាមការសាកសួរជនសង្ស័យ ជាស្ត្រីអូស្ត្រាលី ដែលមានឈ្មោះថា Charles Tammy Alayne ហៅ Tammy ថាធ្លាប់បានប្រកបរបរជួលស្ត្រីពរពោះ នៅប្រទេសថៃកាលពីឆ្នាំ២០១៣ បាន ១៥នាក់ តែថៃបានបិទមុខរបរនេះ ទើបបង្វែរមកកម្ពុជា ប្រមាណជាជាងមួយឆ្នាំហើយ ។នៅកម្ពុជា

ខ្លួនបានទាក់ទងឲ្យស្ត្រីពរពោះ បានចំនួន ២៣នាក់ហើយ និងមានអ្នកដែលបានកើតកូនរួចហើយ ៥នាក់ និងមានទារក៦ ព្រោះមានកូនភ្លោះមួយគូ ។ អ្នកដែលចង់បានកូន បានប្រគល់លុយឲ្យគាត់ ក្នុងកូនមួយនាក់ ៥០.០០០ដុល្លាតែបានប្រគល់ឲ្យស្ត្រីដែលជួលពរពោះ ម្នាក់១០.០០០ ទៅ ១២.០០០ ដុល្លា ព្រោះត្រូវចំណាយលើសកម្មភាព បែបបទ អន្តរការី និងបច្ចេកទេសជាច្រើនទៀត ។ កូនដែលកើតរួចហើយ បានធ្វើសំបុត្រកំណើត បំពេញបែបបទ អន្តោប្រវេសន៍ ចេញទៅអូស្ត្រាលី នៅសល់ពីរនាក់ទៀតដែលមិនទាន់បានចេញ ។

ការបង្ក្រាបនៅរាជធានីភ្នំពេញនេះ គឺពាក់ព័ន្ធនឹងការចោទប្រកាន់ពីព្រះរាជអាជ្ញាក្នុងករណី ~~ក្លែងឯកសារសាធារណៈ~~ និងករណីធ្វើអន្តរការី~~ដើម្បីពរពោះជំនួស~~ ដែលច្បាប់កម្ពុជាបានហាមឃាត់ ។ មិនតែប៉ុណ្ណោះ ក៏ពាក់ព័ន្ធនឹងការនាំចេញ ដែលធ្វើឡើងដោយអន្តរការី ដោយពុំមានអាណាព្យាបាលពិតមកបំពេញបែបបទតាមផ្លូវច្បាប់ គឺអាចជាការរត់ពន្ធ ឬជួញដូរទារក ។

នៅក្នុងតំណាក់កាលនេះ សមត្ថកិច្ច បានប្រើច្បាប់ព្រហ្មទណ្ឌ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងប្រកាសក្រសួងសុខាភិបាល ដែលហាមឃាត់ការធ្វើអន្តរការី ក្នុងការពរពោះជំនួស ។ (តាមខេមរភាព 679- ថ្ងៃទី 24/10/2016)

ផលប៉ះពាល់នៃអំពើនេះ មិនទាន់បានឃើញជាក់ស្តែងនៅឡើយទេ តែបើមិនមានការបង្ក្រាបទេ អំពើនេះនឹងរីកធំឡើង ហើយក៏បានសិក្សាពីប្រទេសនានា ដែលបាន និងកំពុងតែមានការប្រុងប្រយ័ត្នពីបញ្ហានេះ ជាពិសេសបានមើលឃើញពីតម្រូវការរបស់វេជ្ជសាស្ត្រ ឬអ្នកវិទ្យាសាស្ត្រមួយចំនួន ក្នុងការផ្លាស់ប្តូរសរីរាង្គ ការពិសោធន៍ និងគោលបំណងទុច្ចរិតជាច្រើនទៀត ។ កម្ពុជា ក៏ជាប្រទេសហត្ថលេខីនៃអនុសញ្ញា កតិកាសញ្ញា អន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិកុមារ សិទ្ធិមនុស្ស នឹងការប្រឆាំងឧក្រិដ្ឋកម្មនានា ដែលមិនអាចមើលរំលងករណីនេះបានឡើយ ។ រីឯច្បាប់ស្តីពីការពរពោះជំនួស ក៏មិនទាន់បានរៀបចំនៅឡើយ ដែលមិនអាចរង់ចាំបាន ។ ទោះបីជាស្ត្រីអ្នកពរពោះ បានទទួលកម្រៃច្រើនក៏ដោយ តែមិនគួរប្រើប្រាស់មុខរបរនេះ សម្រាប់ជាចំណូលសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រនោះដែរ ។ ច្បាប់ត្រូវតែញែកឲ្យច្បាស់ពីកម្រិតមនុស្សធម៌ និងបទឧក្រិដ្ឋ ។

បញ្ហានៅត្រង់ថា តើស្ត្រី និងទារកដែលនៅក្នុងផ្ទៃ ត្រូវប្រឈមនឹងបញ្ហាអ្វីខ្លះ ពេលដែលករណីនេះ ត្រូវបានបង្ក្រាប ?។

នៅថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នាងខ្ញុំបានកោះប្រជុំមន្ត្រីជំនាញពាក់ព័ន្ធ មាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ការិយាល័យប្រឆាំងការជួញដូរមនុស្សរាជធានី ព្រះអាជ្ញារងរាជធានី តំណាងក្រសួងសុខាភិបាល តំណាងក្រសួង អង្គការពាក់ព័ន្ធដទៃទៀត រួមទាំងតំណាងស្ថានទូតអូស្ត្រាលី ប្រាំមួយរូប ដម្បីពិភាក្សាគ្នារកដំណោះស្រាយ ។

ក្នុងការពិភាក្សា ភាគីអូស្ត្រាលីព្យាយាមគេចពីការទទួលខុសត្រូវ ហើយបកស្រាយតាមច្បាប់អូស្ត្រាលី ដែលចាត់ទុកថា ការពរពោះជំនួស ជាសិទ្ធិឯកជន មិនពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋាភិបាលអូស្ត្រាលីទេ ។ ក្នុងចំណុចនេះ នាងខ្ញុំបានជម្រាបជូនថា ច្បាប់នេះ អាចអនុវត្តបាននៅអូស្ត្រាលី តែមិនអាចយកមកអនុវត្តនៅកម្ពុជាទេ លើសពីនេះទៅទៀត ក៏មានការឃុបឃិតផ្តល់ឯកសារក្លែងក្លាយ និងផ្តល់សញ្ជាតិ ដែលធ្វើឡើងដោយមន្ត្រីស្ថានទូតអូស្ត្រាលី ថែមទៀត ។ដើម្បីដោះ

ស្រាយបញ្ហានេះ នាងខ្ញុំបានស្នើសុំឲ្យភាគីអូស្ត្រាលី សហការជាមួយភាគីរដ្ឋាភិបាលកម្ពុជា លើបីចំណុច ៖

ទី១ សុំឲ្យភាគីអូស្ត្រាលីផ្អាកទទួលការស្នើសុំការពរពោះជំនួសនេះ មកអនុវត្តនៅកម្ពុជាសិន ដើម្បីកុំឲ្យមានការបង្កើតករណីថ្មីទៀត ក្នុងអំឡុងពេលដោះស្រាយករណីដែលមានរួចហើយ

ទី២ ដោះស្រាយករណីដែលកំពុងតែមានក្នុងដៃ គឺកូនដែលកំពុងនៅក្នុងផ្ទៃរបស់ស្ត្រី ១៨នាក់ទៀត និងកូនដែលមិនទាន់បានយកចេញទៅអូស្ត្រាលីនៅឡើយ គឺតម្រូវឲ្យយកថវិកាដែលជនសង្ស័យទទួលបានពីអ្នកចង់បានកូន មកបន្តឧបត្ថម្ភស្ត្រីពរពោះ តាមការសន្យា រហូតដល់កូនកើត និងសុំឲ្យភាគីអូស្ត្រាលី បញ្ជូនអ្នកដែលជាអ្នកចង់បានកូន ឲ្យចេញមុខទទួលខុសត្រូវក្នុងការធ្វើជាឪពុក ឬម្តាយ ចំពោះទារកទាំងនោះ និង

ទី៣ សុំឲ្យមានកិច្ចសហការពីភាគីអូស្ត្រាលី ដើម្បីរៀបចំបែបបទនីតិវិធីរួមគ្នា ឲ្យបានសមស្រប ត្រឹមត្រូវ ដើម្បីដោះស្រាយចំពោះករណីដែលកើតមានរួចហើយ ។ ចំពោះករណីថ្មី គឺត្រូវរង់ចាំឲ្យមានការណែនាំជាថ្មីពីរាជរដ្ឋាភិបាល និងច្បាប់កំណត់ ។

សំណើទាំងនេះ ពុំទាន់បានទទួលចម្លើយត្រឡប់ពីតំណាងស្ថានទូតអូស្ត្រាលីនៅឡើយទេ ។

អាស្រ័យហេតុនេះ នាងខ្ញុំសូមមតិដឹកនាំដ៏ខ្ពង់ខ្ពស់ពីសម្តេចក្រឡាហោម ចំពោះចំណាត់ការបន្ត ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១៦

**រដ្ឋលេខាធិការ**

**ជូ ប៊ុនអេង**

28/11/16

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
ការិយាល័យកណ្តាលប្រឆាំងបទល្មើស
ការិយាល័យប្រឆាំងការជួញដូរមនុស្ស
និងការពារអនីតិជន

លេខ:............./ ១៦

លេខក្នុងការណី.................

# របាយការណ៍សំយោគ

**ស្តីពី** ៖ ករណី អំពើធ្វើជាអន្តរការីនៃអំពើពពោះ និង សុំឲ្យផ្តល់ឯកសារដោយទុច្ចរិត ។

## គោរពជូន
## ឯកឧត្តម ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ

**តាមរយៈ** ៖ **លោកស្នងការរង និងជាប្រធានការិយាល័យកណ្តាលប្រឆាំងបទល្មើស**

**កម្មវត្ថុ** ៖ សំណើសុំបញ្ជូនសំណុំរឿង និង ជនប្រព្រឹត្តល្មើសចំនួន ០៣នាក់ គឺ ៖

១-ឈ្មោះ CHARLES TAMMY LAYNE ហៅ TAMMY ភេទ ស្រី ជនជាតិ អូស្ត្រាលី លិខិតឆ្លងដែនលេខ №674391

២-ឈ្មោះ **ស៊ រិទ្ធ ច័ន្ទចរិយា ហៅ សម្បត្តិ ចរិយា** ភេទ ស្រី ជនជាតិ ខ្មែរ

៣-ឈ្មោះ **ពេញ រិទ្ធី** ភេទ ប្រុស ជនជាតិ ខ្មែរ ដែលបានឃាត់ខ្លួនកាល ពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ តាមដីកាបញ្ជាឲ្យចូលខ្លួនរបស់ លោក សេង ហៀង ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

I-**យោង** ៖ -តាមការបំភ្លឺរបស់ជនរងគ្រោះ ។

-របាយការណ៍មន្ត្រីជំនាញរបស់ការិយាល័យ ។

-ដីកាបញ្ជាឲ្យចូលខ្លួន ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ២០១៦ ។

II-**ហេតុការណ៍** ៖

កាលពីវេលាម៉ោង ១៥ និង ៥០ នាទី ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ អនុវត្តតាមដីកាបញ្ជាឲ្យ ចូលខ្លួនរបស់លោក **សេង ហៀង** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ការិយាល័យ បាន ចុះអនុវត្តដីកាបញ្ជាឲ្យចូលខ្លួន ករណី **អំពើធ្វើជាអន្តរការីនៃអំពើពពោះ និង សុំឲ្យផ្តល់ឯកសារដោយទុច្ចរិត** បាន ឃាត់ខ្លួនជនសង្ស័យចំនួន ០៣នាក់ គឺ៖

១-ឈ្មោះ ស៊ រិទ្ធ ច័ន្ទចរិយា ហៅ សម្បត្តិ ចរិយាល ភេទ ស្រី អាយុ ៣៥ឆ្នាំ ជនជាតិ ខ្មែរ នៅ ចំណុចមុខផ្ទះលេខ៥៤ ផ្លូវលំ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

២-ឈ្មោះ ពេញ រិទ្ធី ភេទ ប្រុស អាយុ ២៨ឆ្នាំ ជនជាតិ ខ្មែរ នៅចំនុចផ្ទះលេខD៥ ផ្លូវលំ សង្កាត់ ក្រាំងធ្នុង ខណ្ឌសែនសុខ រាជធានីភ្នំពេញ

៣-ឈ្មោះ CHARLES TAMMY LAYNE ហៅ TAMMY ភេទ ស្រី ជនជាតិ អូស្ត្រាលី លិខិតឆ្លងដែនលេខ №674391 នៅចំនុចភ្លើងស្តុបផ្សារដើមហ៊ុយ សង្កាត់ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានីភ្នំពេញ ។ យកមក កាន់ការិយាល័យដើម្បីធ្វើការសាកសួរ និង ស្រាវជ្រាវ ។

**III.ការស៊ើបអង្កេត ៖**

- តាមការបំភ្លឺរបស់ ឈ្មោះ ហោ វណ្ណី ភេទ ស្រី អាយុ ៣៥ឆ្នាំ ជនជាតិ ខ្មែរ (ជនរងគ្រោះ) បានឲ្យដឹងថា ៖ ខ្លួនបានស្គាល់នារី ម្នាក់ ឈ្មោះ ស្រីអូន បានមកផ្សព្វផ្សាយរកនារីណាដែលត្រូវការពរពោះបង្កើតកូនយកលុយ ដោយក្នុងកូនម្នាក់បានលុយចំនួនពី ៨០០០ដុល្លា ទៅ ១០០០០ដុល្លា ដោយខ្លួនមាន ជីវភាពក្រីក្រ ក៏សំរេចចិត្តទៅចុះឈ្មោះស៊ីឈ្នួល ពរពោះឲ្យគេ ហើយបានណាត់ជួបគ្នានៅ មន្ទីរពេទ្យសម្រាកព្យាបាលកម្ពុជា ដើម្បីសាក ល្បងបញ្ចូលមេជីវិតចំនួន ០៣ដង ទើបដឹង នៅពេល ដឹងថាមានកូនហើយ ទើបខ្លួនបាន ទទួលលុយចំនួន ៤០០ដុល្លា ក្នុងមួយខែ រហូតដល់ ពេលកូនកើតមកទើបគេឲ្យលុយទាំង អស់ ។ នៅពេលខ្លួនកំពុងពរពោះ គឺខ្លួន បានទៅជួបជាមួយឈ្មោះ ចរិយា ភេទ ស្រី អាយុប្រហែល ៣៥ឆ្នាំ ជាអ្នកនាំទៅធ្វើកាត ធនាគារ ATMនិងជាអ្នករៀបចំឯកសារ និងឈ្មោះ TAMMY ភេទ ស្រី អាយុប្រហែល ៤២ឆ្នាំ ជាគ្រូពេទ្យមកពីប្រទេសអូស្ត្រាលី ហើយឥឡូវនេះខ្លួនបានកើតកូនស្រីបានម្នាក់ នៅមន្ទីរពេទ្យលុច្ស កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០១៦ ដោយខ្លួនពុំបានឃើញមុខកូនទេ ហើយអ្នកដែល រត់ការធ្វើសំបុត្រកំណើតសៀវភៅស្នាក់នៅ គឺឈ្មោះ **ធី** ភេទប្រុស អាយុ ប្រហែល ៣៦ឆ្នាំ ។
- តាមការបំភ្លឺរបស់ ឈ្មោះ **ឈន ស្រីរ័ត្ន** ភេទ ស្រី អាយុ ៣០ឆ្នាំ ជនជាតិ ខ្មែរ (ជនរងគ្រោះ) បានឲ្យដឹងថា ៖ ខ្លួនបានស្គាល់ បុរសម្នាក់ឈ្មោះ **រិទ្ធី** ភេទ ប្រុស អាយុប្រហែល ៣០ឆ្នាំ បានណែនាំឲ្យទៅមន្ទីរពេទ្យ សម្រាកព្យាបាលកម្ពុជាដើម្បីដាក់បញ្ចូលមេជីវិត ក្រោយពីដាក់បញ្ចូលចំនួន **០២**ដង រួចមក ឃើញថា ខ្លួនបានដាក់មេជីវិតជាប់ត្រូវពរពោះ ពេលនោះឈ្មោះ **សម្បត្តិ ចរិយា** ភេទ ស្រី អាយុប្រហែល **៣០**ឆ្នាំ ជនជាតិ ខ្មែរ កាន់ទូរស័ព្ទលេខ ០៨៦ ៧៥១ ២០៩ ជាអ្នកសម្រប សម្រួលធ្វើការងារឲ្យជនបរទេសម្នាក់ ឈ្មោះ **TAMMY** ភេទ ស្រី អាយុប្រហែល ៥០ឆ្នាំ ជនជាតិ អូស្ត្រាលី ដែលជាអ្នកចំណាយថវិកាលើការបញ្ចូលមេជីវិតដើម្បីពរពោះ រហូតដល់ កើតកូនរួច គឺបានតំលៃ **១០០០០**ដុល្លា ដោយគេបើកលុយឲ្យក្នុងមួយខែចំនួន **៤០០**ដុល្លា ខ្លួនបានកើតកូនស្រីម្នាក់កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ នៅមន្ទីរពេទ្យសម្រាក ព្យាបាលលុច្ស ពេលកើតរួចទារកនោះត្រូវបានឪពុកជាជនជាតិ អូស្ត្រាលី បានមកយកទៅ មើលថែទាំ ដោយគ្រាន់តែឲ្យខ្លួនថតរូបជាមួយទារកនោះប៉ុណ្ណោះ ។
- តាមការបំភ្លឺរបស់ ឈ្មោះ **មិត្ត ស៊ីថន** ភេទ ស្រី អាយុ ៣៣ឆ្នាំ ជនជាតិ ខ្មែរ (ជនរងគ្រោះ) បានឲ្យដឹងថា ៖ ខ្លួនបានស្គាល់ បុរសម្នាក់ ឈ្មោះ **រិទ្ធី** ភេទ ប្រុស អាយុប្រហែល ៣០ឆ្នាំ បានណែនាំឲ្យខ្លួនយកឯកសារ ទៅដាក់នៅមន្ទីរពេទ្យសម្រាកព្យាបាលកម្ពុជា រួចហើយ ឈ្មោះ **រិទ្ធី** បានណែនាំខ្លួនឲ្យស្គាល់ ឈ្មោះ **សម្បត្តិ ចរិយា** ភេទ ស្រី អាយុប្រហែល **៣០**ឆ្នាំ ជនជាតិ ខ្មែរ កាន់ទូរស័ព្ទលេខ ០៨៦ ៧៥១ ២០៩ ជាអ្នកសម្របសម្រួលធ្វើការងារឲ្យ ជន

បរទេសម្នាក់ឈ្មោះ **TAMMY** ភេទស្រី អាយុប្រហែល ៥០ឆ្នាំ ជនជាតិ អូស្ត្រាលី ដែលជាអ្នកចំណាយថវិកាលើការបញ្ចូល មេជីវិតដើម្បីពរពោះ រហូតដល់កើតកូនរួច គឺបានតំលៃ **១០០០០**ដុល្លា ដោយគេបើកលុយ ឲ្យក្នុងមួយខែចំនួន **៤០០**ដុល្លា ខ្លួនបានកើតកូនស្រីម្នាក់កាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៦ នៅមន្ទីរពេទ្យសម្រាកព្យាបាលលុច្ស ហើយឈ្មោះ **រិទ្ធី** ជាអ្នកធ្វើឯកសារទារក ទាំងអស់ ដោយកែប្រែឈ្មោះឪពុកជាជនជាតិអូស្ត្រាលី ហើយក្រោយពីកើតកូនបានកន្លះខែ ទើបឈ្មោះ **TAMMY** បានយកលុយប្រគល់ឲ្យខ្លួនគ្រប់ចំនួននៅធនាគារវឌ្ឍនៈ ។

- តាមការបំភ្លឺរបស់ ឈ្មោះ **គួយ សូលី** ភេទ ប្រុស អាយុ ៣៤ឆ្នាំ ជនជាតិ ខ្មែរ (ប្តីជនរងគ្រោះ)បានឲ្យដឹងថា ៖ ខ្លួនធ្វើការជាជាងសំណង់ហើយនៅថ្ងៃមួយក្នុងឆ្នាំ២០១៦ ប្រពន្ធខ្លួនឈ្មោះ **មិត្ត ស៊ីថន** បានមកសុំខ្លួនថា ចង់ពរពោះឲ្យគេតាមរយៈក្រុមហ៊ុនមួយនៅ ក្នុងរាជធានីភ្នំពេញ ដោយទទួលបានថ្លៃពរពោះ ចំនួន **១០០០០**ដុល្លា ពេលនោះដោយជីវភាពមានការខ្វះខាត ចង់បានលុយមកទំនប់ បម្រុងក្នុងគ្រួសារទើបខ្លួនយល់ព្រម បន្ទាប់មកប្រពន្ធខ្លួនក៏បានទៅមន្ទីរពេទ្យសម្រាកព្យាបាលកម្ពុជា ដើម្បីដាក់មេជីវិតសាកល្បង ហើយប្រពន្ធខ្លួនបានប្រាប់ថាជាប់មេជីវិតហើយ ទើបគេឲ្យទៅបើកលុយជារៀងរាល់ខែនៅធនាគារវឌ្ឍនៈ រហូតមកដល់ថ្ងៃទី៣០ ខែ មេសា ឆ្នាំ២០១៦ ប្រពន្ធខ្លួនបានទៅសម្រាលកូននៅមន្ទីរពេទ្យលុច្ស ចំពោះឯកសារដែលពាក់ព័ន្ធ គឺខ្លួនមិនបានដឹងទេ គឺខាងក្រុមហ៊ុនជាអ្នករៀបចំឲ្យទាំងអស់ ។
- តាមការបំភ្លឺរបស់ ឈ្មោះ **វ៉ាន់ គន្ធ** ភេទ ប្រុស អាយុ ៣៦ឆ្នាំ ជនជាតិ ខ្មែរ (ប្តីជនរងគ្រោះ) បានឲ្យដឹងថា ៖ ប្រពន្ធខ្លួនបាន មកសុំខ្លួនថា ចង់ពរពោះឲ្យគេ តាមរយៈក្រុមហ៊ុនមួយនៅក្នុងរាជធានីភ្នំពេញ ដោយទទួល បានថ្លៃពរពោះចំនួន **៨០០០**ដុល្លា ទៅ **១០០០០**ដុល្លា តែគេបើករាល់ខែ ក្នុងមួយខែ **៤០០**ដុល្លា ពេលនោះដោយជីវភាពខ្វះខាត ចង់បានលុយមកទំនប់បម្រុងក្នុងគ្រួសារទើបខ្លួនយល់ព្រម បន្ទាប់មកប្រពន្ធខ្លួនក៏បានទៅមន្ទីរពេទ្យសម្រាកព្យាបាលកម្ពុជា ដើម្បីដាក់ មេជីវិតសាកល្បង ហើយប្រពន្ធខ្លួនបានប្រាប់ថាជាប់ មេជីវិតហើយ រហូតមកដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៦ ប្រពន្ធខ្លួនបានទៅសម្រាល បានកូនស្រីម្នាក់នៅមន្ទីរពេទ្យលុច្ស ចំពោះ ឯកសារដែលពាក់ព័ន្ធគឺខ្លួនមិនបានដឹងទេ គឺខាងក្រុមហ៊ុនជាអ្នករៀបចំឲ្យទាំងអស់ ។
- របាយការណ៍មន្ត្រីជំនាញការិយាល័យបានអោយដឹងថា (លើកទី១) ៖ ក្រោយពីបានទទួលបទបញ្ជាពីថ្នាក់ដឹកនាំការិយាល័យឲ្យចុះធ្វើការស្រាវជ្រាវស៊ើបអង្កេត ទៅលើឈ្មោះ **សម្បត្តិ ចរិយា** ភេទ ស្រី អាយុប្រហែល ៣០ឆ្នាំ ជនជាតិ ខ្មែរ មានមុខរបរ ពេទ្យឆ្មប នៅមន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ និង ជាគ្រូពេទ្យប្រចាំនៅមន្ទីរពេទ្យសម្រាកព្យាបាលកម្ពុជាបានដើររកស្រីៗ ដែលអាចពរពោះបង្កើតកូនបានហើយនាំមកជួបស្ត្រីបរទេសម្នាក់ទៀត ឈ្មោះ **ធីមមី** (TAMMY) ភេទ ស្រី អាយុ ប្រហែលជាង ៤០ឆ្នាំ ជនជាតិ អាឡឺម៉ង់ កាន់លិខិតឆ្លងដែន លេខ ៩៥១៦២ ៨៩៧០ ដោយក្នុងការពរពោះបង្កើតកូនបានចំនួនមួយនាក់គេឲ្យលុយថ្លៃ ឈ្នួលតំលៃ ១០០០០ដុល្លា និង លុយថ្លៃបាញ់បញ្ចូលមេជីវិតតំលៃ ៦០០០ដុល្លា និង លុយថ្លៃថែរក្សាផ្ទៃ ពោះតាំងពីមានកូនពរពោះរហូតបង្កើតកូនបានឈ្មោះ

ធីម មី ជាអ្នក ចំណាយទាំងអស់ ក៏ប៉ុន្តែពេលបង្កើតកូនបានហើយពួកគេនាំយកទារកនោះទៅណាទៀត នោះ យើងខ្ញុំពុំទាន់បានដឹងទេ។

- របាយការណ៍មន្រ្តីជំនាញការិយាល័យបានអោយដឹងថា (លើកទី២) ៖ កាលពីថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ដោយបានទទួលបទបញ្ជាពីថ្នាក់ការិយាល័យបានឲ្យខ្ញុំបាទចុះទៅស្រាវជ្រាវករណី នារីខ្មែរស៊ីឈ្នួលពរពោះដែលមានអាយុចាប់ពីអាយុ២២ឆ្នាំឡើងទៅជាលទ្ធផលបានឲ្យដឹងថារាល់ថ្ងៃចុងខែខ្ញុំបាទតែងតែសង្កេតឃើញមាននារីខ្មែរចំនួន ពី១០ នាក់ ទៅ ១៥ឆ្នាំ ទៅពិនិត្យសុខភាពនៅមន្ទីរព្យាបាលកម្ពុជាដែលមានទីតាំងជាប់សាលារៀនស៊ី សុវត្ថិ ពេលពិនិត្យ សុខភាពរួចហើយនារីខ្មែរទាំងអស់នោះមានអ្នកខ្លះជិះម៉ូតូកង់បី និងអ្នក ខ្លះជិះម៉ូតូឌុបបានចេញ ដំណើរទៅ AMPATMAN ឈ្មោះផាមផាលេស ដែលមានទីតាំង ផ្លូវលេខ ៧៥ សង្កាត់ស្រះចក ខណ្ឌដូនពេញ បន្ទប់លេខ ៥០២ ដើម្បីយកសេវា ពរពោះ ។
- របាយការណ៍មន្រ្តីជំនាញការិយាល័យបានអោយដឹងថា (លើកទី៣) ៖ កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៦ យើងខ្ញុំបានទទួលបទបញ្ជាពីថ្នាក់ដឹកនាំការិយាល័យឲ្យចុះធ្វើការ ស្រាវជ្រាវស៊ើបអង្កេតនៅក្នុងអាគារខនដូ ផាមផាលេស សង្កាត់ស្រះចក ខណ្ឌដូនពេញ ។ តាមការសាកសួរមនុស្សស្រីៗនៅក្នុងបន្ទប់លេខ ៥០២ មានបន្ទប់ពីរតូចៗមានស្រីៗចំនួន ០៦ នាក់ ក្នុង នោះចុងភៅ ០១នាក់ ស្រីៗពរពោះបានរយៈពេលពីរខែចំនួន ០២នាក់ អ្នក ទើបបាញ់ទឹកស្តែម ចូលបានរយៈពេល០៧ថ្ងៃទៅ១០ថ្ងៃចំនួន០៤នាក់ ហើយពួកស្រីៗ បាននិយាយប្រាប់ថាគេមាន ធ្វើកិច្ចសន្យាថា ពេលបង្កើតកូនមកស្អាតគ្រប់លក្ខណៈគេ បញ្ចូលលុយក្នុងគណនីយឲ្យចំនួន ១០០០០ដុល្លា តែបើកូននោះកើតមកមិនគ្រប់ លក្ខណៈពិការផ្នែកអ្វីមួយនោះគេកាត់ចាប់ពី ២០ ភាគរយទៅ៥០ភាគរយ ។ ប៉ុន្តែពេលគេ បាញ់បញ្ចូលទឹកស្តែមដំបូងគេឲ្យលុយលើកទឹក ចិត្តចំនួន ៣០០ដុល្លា និងឲ្យថ្លៃសាហុយ ធ្វើដំណើរចំនួន ៥០ដុល្លា ទៀត ។
- របាយការណ៍មន្រ្តីជំនាញការិយាល័យបានអោយដឹងថា (លើកទី៤) ៖ កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ ដោយមានការអនុញ្ញាតពីលោកនាយការិយាល័យឲ្យខ្ញុំបាទចុះស្រាវជ្រាវស៊ើបអង្កេតករណី ស៊ីឈ្នួលពរពោះ លទ្ធផលបានឲ្យដឹងថា៖ កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ ឈ្មោះ ឈន ស្រីរ័ត្ន ភេទ ស្រី អាយុ ៣០ឆ្នាំ បានចូលទៅសំរាលកូន នៅគ្លីនិកលុច្ស បន្ទប់ VI V លេខ ២០ ដែលមានទីតាំងផ្លូវនរោត្តម សង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ រហូតដល់ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៦ ទើបឈ្មោះ ឈន ស្រីរ័ត្ន ចេញពី គ្លីនិកត្រលប់ទៅលំនៅដ្ឋានវិញ ដោយមិនយកទារកទៅជាមួយទេ ។
- របាយការណ៍មន្រ្តីជំនាញការិយាល័យបានអោយដឹងថា (លើកទី៥) ៖ បន្ទាប់ពីទទួលបទបញ្ជាពីថ្នាក់ដឹកនាំការិយាល័យឲ្យចុះធ្វើការស្រាវជ្រាវស៊ើបអង្កេតទៅលើឈ្មោះ CHARLES TAMMY LAYNE ហៅ TAMMY ភេទ ស្រី ជនជាតិ អូស្រ្តាលី ឧស្សាហ៍ចេញចូលប្រទេសកម្ពុជាជាញឹកញាប់ ប៉ុន្តែពុំមានមុខរបរឬទីលំនៅពិតប្រាកដទេ ហើយឈ្មោះ សម្បត្តិ ចរិយា ភេទ ស្រី ជនជាតិ ខ្មែរ មានមុខរបរ ជាពេទ្យឆ្មប នៅមន្ទីរបង្អែកភ្នំពេញ ប៉ុន្តែពុំមានទីលំនៅពិត ប្រាកដទេ ចំណែកឯឈ្មោះ ពេញ រិទ្ធី ភេទ ប្រុស ជនជាតិ ខ្មែរ បច្ចុប្បន្ន ក៏ពុំមានមុខរបរ និង ទីលំនៅពិតប្រាកដដែរ ។

- តាមចម្លើយសារភាពរបស់ឈ្មោះ សំរិទ្ធ ច័ន្ទចរិយា ហៅ សម្បត្តិ ចរិយា ភេទ ស្រី អាយុ ៣៥ ឆ្នាំ ជនជាតិ ខ្មែរ (ជនសង្ស័យ) បានឲ្យដឹងថា ៖ ខ្លួនបានមកធ្វើការនៅក្រុមហ៊ុន NEW GENERTI C រកស៊ីជួល ស្ត្រីឲ្យពពោះ ហើយតួនាទីខ្លួនជា អ្នកពិនិត្យសុខភាពស្ត្រីស៊ីឈ្នួលពពោះ ហើយខ្លួនទទួល បានប្រាក់ខែចំនួន ២០០ដុល្លា ហើយប្រធានក្រុមហ៊ុនឈ្មោះ JOSE អាយុ ៤០ឆ្នាំជាង ជនជាតិ ចិន ។ ខ្លួនធ្វើការនៅទីនេះបានរយៈពេលបីខែ រួច ខ្លួនក៏បានឈប់ធ្វើការ តែក្រោយមក ខ្លួនក៏បានស្គាល់ឈ្មោះ ពេញ រិទ្ធី ភេទ ប្រុស អាយុ ៣០ឆ្នាំជាង ហើយគាត់(រិទ្ធី) ក៏បាននាំ ខ្លួនឲ្យស្គាល់ឈ្មោះ ថម មី ភេទ ស្រី អាយុ ប្រហែល៤០ឆ្នាំ ជនជាតិ អូស្ត្រាលី តួនាទីគាត់ គឺជួយដល់អ្នកដែលអសមត្ថភាពគ្មាន កូណ ពេលខ្លួនមកធ្វើការជាមួយគាត់(ថម មី) ឲ្យខ្លួនធ្វើការ ជាអ្នកនាំស្ត្រីស៊ីឈ្នួលពពោះ ទៅពិនត្យសុខភាពនៅតាមមន្ទីរពេទ្យតាមបញ្ជារបស់ ថម មី ហើយខ្លួនជាអ្នកបកប្រែភាសា ឲ្យ ថម មី ខ្លួនទទួលបានប្រាក់ខែចំនួន ២០០ដុល្លា ខ្លួនជូន ស្ត្រីដែលស៊ីឈ្នួលពពោះទៅ ពិនិត្យសុខភាពនៅមន្ទីរពេទ្យកម្ពុជា និង មន្ទីរពេទ្យវឌ្ឍនៈបាន ចំនួន ៥២នាក់ ហើយជាប់ បាន ១២នាក់ ហើយក្នុងម្នាក់ស្ត្រីស៊ីឈ្នួលពពោះដែលពិនិត្យ សុខភាពជាប់ ឈ្មោះ ថម មី ឲ្យលុយក្នុងម្នាក់ ១០០០០ដុល្លា ពេលទៅពិនិត្យសុខភាពស្ត្រី ពពោះមានសុខភាពល្អ គឺ ពេទ្យបញ្ចូលមេជីវិតឲ្យ ហើយឈ្មោះ ថម មី បានឲ្យលុយទៅស្ត្រី ស៊ីឈ្នួលពពោះ ចំនួន ៣០០ដុល្លា រួចពីរសប្ដាហ៍ក្រោយមកស្ត្រីដែលបញ្ចូលមេជីវិតទៅ ពិនិត្យសុខភាពម្ដងទៀត មើលថាមានកូនរឺគ្មានកូន តែបើមានកូន ឈ្មោះ ថម មី ឲ្យលុយ ទៅស្ត្រីពពោះ ចំនួន ៤០០ដុល្លា ទៀត ហើយរាល់ខែ ឈ្មោះ ថម មី ឲ្យលុយទៅស្ត្រីពពោះ ដែលមានកូន ចំនួន ៤០០ដុល្លា រហូតដល់កូនកើត ទើបឲ្យបង្គ្រប់ចំនួន ១០០០០ដុល្លា ចំពោះមេជីវិត ឈ្មោះ ថម មី បាន មកពីណាខ្លួនពុំដឹងទេ ព្រោះឈ្មោះ ថម មី គេនិយាយ ជាមួយពេទ្យ ចំពោះ ស្ត្រីស៊ីឈ្នួលពពោះឈ្មោះ មិត្ត ស៊ីថន ដែលមន្ទីរពេទ្យដាក់ឈ្មោះ សេន ឡេសលីរូបិតខេរី ភេទ ប្រុស អាយុ ៣៥ឆ្នាំ ជនជាតិ អូស្ត្រាលី ដាក់ជាឪពុកគឺឈ្មោះ ថម មី ជាអ្នកឲ្យឈ្មោះ ទៅខាងមន្ទីរពេទ្យដើម្បីចេញលិខិតទៅធ្វើសំបុត្រកំណើត ហើយសំបុត្រ កំណើតឈ្មោះ ពេញ រិទ្ធី ជាអ្នកធ្វើអស់ប៉ុន្មានខ្លួនពុំដឹងទេ ចំពោះស្ត្រីស៊ីឈ្នួលពពោះឈ្មោះ កក្កដា ភេទ ស្រី ដែលឈ្មោះ សារឿនជាអ្នកនាំមកឲ្យឈ្មោះ ថម មី ក្នុងស្រីម្នាក់ឈ្មោះ ថម មី ឲ្យលុយ ចំនួន ៤០០ដុល្លា ។
- តាមចម្លើយសារភាពរបស់ឈ្មោះ ពេញ រិទ្ធី ភេទ ប្រុស អាយុ ២៨ឆ្នាំ ជនជាតិ ខ្មែរ (ជនសង្ស័យ) បានឲ្យដឹងថា ៖ ខ្លួនស្គាល់ជនបរទេសឈ្មោះ ថម មី ភេទ ស្រី អាយុ ប្រហែល ៤៦ឆ្នាំ ជនជាតិ អូស្ត្រាលី និង ឈ្មោះ ចរិយា ភេទ ស្រី អាយុជាង៣០ឆ្នាំ ជនជាតិ ខ្មែរ ប្រហែល៦ខែមកហើយ គឺស្គាល់តាមរយៈមិត្តភ័ក្ត្រ ឈ្មោះ ហេង ដែលធ្វើការនៅ ប្រទេសថៃ ហើយឈ្មោះ ថម មី នេះជាភ្នាក់ងារនាំអតិថិជន និងជាអ្នកចំណាយលើការ បញ្ចូលមេជីវិត ដើម្បីពពោះបង្កើតកូននិងលើឯកសារផ្សេងៗ ចំណែកឯឈ្មោះ ចរិយា ជាអ្នក បកប្រែសំបេសំរួលនិងជូនស្រីៗទៅពេទ្យ ។ កន្លងមកខ្លួនធ្លាប់បានណែនាំនិងជូនស្រីៗខ្មែរ ទៅជួបឈ្មោះ ថម មី នៅមន្ទីរពេទ្យសំរាកព្យាបាលកម្ពុជាបានប្រហែលចំនួន ០៥ទៅ ០៦នាក់ កងនោះមានមាក់មកពីខេតកំពង់ចាម ដែលសើៗទាំងនោះគេរមកបពាលមេជីវិត ដើមីព

ពោះបង្កើតកូន ហើយក្នុងម្នាក់ពេលពពោះរហូតបង្កើតកូន គឺទទួលបានលុយម្នាក់ ចំនួន ១០០០០ដុល្លា ពីឈ្មោះ ថម មី ហើយស្ត្រីពពោះដែលខ្លួននាំមកជួបឈ្មោះ ថម មី បានឲ្យលុយខ្លួនចំនួន ៥០០ដុល្លា និងឈ្មោះ ថម មី បានឲ្យលុយមកខ្លួនចំនួន ៤០០ដុល្លា ។ ក្រៅពីនេះខ្លួនជាអ្នកទទួលធ្វើសំបុត្រកំណើតឲ្យទារកដែលបានកើតមក គឺក្នុងទារកម្នាក់ខ្លួនយកពីឈ្មោះ ថម មី ចំនួន ៦០០ដុល្លា បើកកូនភ្លោះយក ៨០០ដុល្លា រួចខ្លួនយកទៅធ្វើសំបុត្រកំណើតនៅឯសង្កាត់ គឺផ្តល់ឲ្យសង្កាត់ក្នុងសំបុត្រកំណើតម្នាក់ ៣០០ដុល្លា ហើយឯកសារដែលខ្លួនយកទៅរត់ធ្វើសំបុត្រកំណើតឲ្យទារកគឺខ្លួនយកពីឈ្មោះ ថម មី ដូចជាសំបុត្រពេទ្យចុះថ្ងៃទី៥ខែឧសភាឆ្នាំ២០១៦ ដែលមានប្រពន្ធឈ្មោះ មិត្ត ស៊ីថន និង ប្តីឈ្មោះ សេន ឡេសលីរ៉ូប៊ឺតខៃរី ជនជាតិ អូស្ត្រាលី គឺខ្លួនបានមកពីឈ្មោះ ថម មី ឲ្យខ្លួនយកទៅរត់ធ្វើសំបុត្រកំណើតឲ្យទារកដែលកើតមក ។ ហើយកន្លងមកខ្លួនបានទទួលរត់ការជូនឪពុក ម្តាយ និង ទារក ដែលខ្លួនធ្វើសំបុត្រកំណើតរួចហើយនោះ បានទៅកន្លែងធ្វើបែបបទសុំវីសា គឺខ្លួនទទួលយកលុយពីឈ្មោះ ថម មី បើកូនម្នាក់ខ្លួនយក ៧០០ដុល្លា បើកូនភ្លោះ ១៣៥០ដុល្លា ហើយខ្លួនត្រូវបង់ទៅឲ្យកន្លែងសុំវីសា ៣៥ដុល្លា ហើយខ្លួនបានជូនទៅ ០៤នាក់ ក្នុងនោះបានចេញទៅប្រទេសអូស្ត្រាលីបានចំនួន ០២នាក់ នៅសល់ ០២ នាក់ទៀតពុំទាន់បានចេញ ហើយចំណែកទារកម្នាក់ទៀតដែលទើបកើតគឺខ្លួនបានធ្វើសំបុត្រកំណើតឲ្យហើយ តែពុំទាន់បានទៅបំពេញបែបបទសុំវីសាទេ ។ លុះមកដល់ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ម៉ោងប្រហែល ១៥ និង ៤០នាទី ពេលដែលខ្លួនកំពុងនៅក្នុងផ្ទះស្នាក់នៅខាងលើក៏ត្រូវបានសមត្ថកិច្ចធ្វើការនាំខ្លួនមកកាន់ទីនេះតែម្តង ។

- តាមចម្លើយសារភាពរបស់ឈ្មោះ CHARLES TAMMY ALAYNE ហៅ TAMMY ភេទ ស្រី អាយុ ៤៩ឆ្នាំ ជនជាតិ អូស្ត្រាលី (ជនសង្ស័យ) បានឲ្យដឹងថា ៖ កាលពីឆ្នាំ ២០១៣ ខ្លួន បានទៅប្រកបមុខរបរជួលស្ត្រីឲ្យបង្កើតកូន នៅប្រទេសថៃ បានចំនួន ១៥ នាក់ ហើយ ក្រោយមកប្រទេសថៃគេបិទ ខ្លួនក៏មកប្រទេសកម្ពុជាបានរយៈពេលប្រហែល ១២ ខែ ទៅ ១៤ខែ មកហើយ ខ្លួនបានរកស្ត្រីខ្មែរជួលឲ្យពពោះបង្កើតកូនឲ្យបានចំនួន ២៣នាក់ នាំ យកចេញទៅក្រៅបានចំនួន ៦នាក់ ក្នុងនោះកូនភ្លោះមួយនាក់ ដោយតំលៃខ្លួនទទួលយក ពីគ្រួសារចង់បានកូនមួយអ្នកថ្លៃ ៥០០០០ដុល្លា មកជួលស្ត្រីឲ្យពពោះបង្កើតកូនឲ្យ មួយម្នាក់តំលៃ ១០០០០ដុល្លា ទៅ ១២០០០ដុល្លា បូកទាំងការព្យាបាលថែទាំ មើល ទារក ខ្លួនត្រូវចំណាយអស់ ២៤០០០ដុល្លា ឯការចាក់បញ្ចូលទឹកមេជីវិតបុរសក្នុងមួយ នាក់តំលៃ ៥០០០ដុល្លា ទៅ ៧០០០ដុល្លា នៅមន្ទីរពេទ្យ FFPP បានមួយនាក់និងនៅ មន្ទីរពេទ្យ Fcc នៅលើអាគារវឌ្ឍនៈជាន់ទី២ បាន២០នាក់ ។ ពេលកើតកូនយកទៅបង្កើត នៅមន្ទីរពេទ្យសំរាកព្យាបាលលុច្សក្នុងកូនមួយនាក់តំលៃ ១៥០០ដុល្លា ទៅ ២០០០ដុល្លា ចំពោះអ្នកដែលបានជួយរកស្ត្រីមកស៊ីឈ្នួលពពោះបង្កើតកូនមួយនាក់ខ្លួនឲ្យ ៤០០ដុល្លា ចំពោះឈ្មោះ ពេញ រិទ្ធី ជួយរត់ការធ្វើសំបុត្រកំណើតឲ្យទារកមួយនាក់ ខ្លួនឲ្យតំលៃ ៦០០ដុល្លា ទៅ ៨០០ដុល្លា និង ជួយដឹកក្មេងចេញទៅបំពេញបែបបទនៅនាយកដ្ឋានអន្តោប្រវេសន៍ ខ្លួនឲ្យតំលៃ៧០០ដុល្លា និង ជួយរត់ការពន្យាលិខិតឆ្លងដែន ។ រីឯឈ្មោះ ចរិយា ខនឲជេយធើការជាមយគីនិក ជយបកបែភាសា ជយមើលថៃសើនៅតាមគីនិកខន

ឲ្យប្រាក់ខែចំនួន ៦៥០ដុល្លា ក្នុងមួយខែ រហូតដល់ខែ កក្កដា ឆ្នាំ២០១៦ ឈប់ធ្វើការជាមួយ ខ្លួនហើយ ព្រោះ ឈ្មោះ ចរិយា សំរាលកូន ។ ហើយឈ្មោះ មិត្ត ស៊ីថនមានប្តីឈ្មោះ សេន ឡេសលីរ៉ូប៊ិតខៃវី ដែលបានបង្កើតកូន ហើយចេញពីមន្ទីរពេទ្យព្យាបាលលុច្សនៅ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ នោះ ខ្លួនបានឲ្យឈ្មោះ ពេញ រិទ្ធី យកកំបុត្រចេញពីមន្ទីរពេទ្យនេះ ទៅរត់ការធ្វើសំបុត្រកំណើតឲ្យទារក ។

VI -**តុល្យភាព**៖ផ្អែកតាមរបាយការណ៍មន្ត្រីជំនាញការិយាល័យ និង តាមការបំភ្លឺឈ្មោះ ១-ឈ្មោះ ហោ វណ្ណី , ២-ឈ្មោះ ឈន ស្រីវត្ត , ៣-ឈ្មោះ មិត្ត ស៊ីថន , ៤- ឈ្មោះ គួយ សីលី , ៥-ឈ្មោះ វ៉ាន់ គន្ធ និង ចម្លើយសារភាពរបស់ជនសង្ស័យ ឈ្មោះ ១- ឈ្មោះ **ស៉រិទ្ធ ច័ន្ទចរិយា ហៅ សម្បត្តិ ចរិយា** , ២-ឈ្មោះ **ពេញ រិទ្ធី** , ៣- ឈ្មោះ CHARLES TAMMY LAYNE ហៅ TAMMY យើង សន្និដ្ឋានថា ៖

១-ឈ្មោះ **ស៉រិទ្ធ ច័ន្ទចរិយា ហៅ សម្បត្តិ ចរិយា** ភេទ ស្រី ជនជាតិ ខ្មែរ

២-ឈ្មោះ **ពេញ រិទ្ធី** ភេទ ប្រុស ជនជាតិ ខ្មែរ

៣-ឈ្មោះ CHARLES TAMMY LAYNE ហៅ TAMMY ភេទ ស្រី ជនជាតិ អូស្ត្រាលី ពិតជាបានប្រព្រឹត្តអំពើធ្វើជាអន្តរការីនៃអំពើពពោះនិងសុំឲ្យផ្តល់ឯកសារដោយទុច្ចរិតពិតប្រាកដមែន ។

V-**សំណូមពរ**៖សុំបញ្ជូនសំណុំរឿង និង ជនប្រព្រឹត្តល្មើសចំនួន ០៣ នាក់ គឺ៖

១-ឈ្មោះ **ស៉រិទ្ធ ច័ន្ទចរិយា ហៅ សម្បត្តិ ចរិយា** ភេទ ស្រី ជនជាតិ ខ្មែរ

២-ឈ្មោះ **ពេញ រិទ្ធី** ភេទ ប្រុស ជនជាតិ ខ្មែរ

៣-ឈ្មោះ CHARLES TAMMY LAYNE ហៅ TAMMY ភេទ ស្រី ជនជាតិ អូស្ត្រាលី ទៅសាលាដំបូងរាជធានីភ្នំពេញដើម្បីចាត់ការបន្តតាមនីតិវិធី ។

សូម **ឯកឧត្តម ព្រះរាជអាជ្ញា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ ,ថ្ងៃទី..........ខែ វិច្ឆកា ឆ្នាំ ២០១៦

**នាយការិយាល័យ**

បានឃើញ និង គោរពជូន

**ឯកឧត្តម ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ**

ដើម្បីចាត់ការបន្តតាមនីតិវិធី ។

រាជធានីភ្នំពេញ , ថ្ងៃទី.............ខែ............ឆ្នាំ ២០១៦

**ស្នងការរង និងជា**

**ប្រធានការិយាល័យកណ្តាលប្រឆាំងបទល្មើស**